# លោក ខៀវ កាញារីទ្ធ នឹងទៅកាន់បិណ្ឌ

# នៅវត្តនគររាជបុរី ខេត្តព្រះត្រពាំង ដែនដីខ្មែរកម្ពុជាក្រោម



លោក ខៀវ កាញារីទ្ធ អ្នកនាំពាក្យរដ្ឋាភិបាល និងជារដ្ឋមន្ត្រីក្រសួងព័ត៌មាន

មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជា បានផ្តួចផ្តើមទៅកាន់បិណ្ឌនៅវត្តមួយកន្លែងក្នុងខេត្តព្រះត្រពាំង ដែនដីខ្មែរកម្ពុជាក្រោម នៅដើមខែកញ្ញា ឆ្នាំ២០០៩ ខាងមុខនេះ ។

លោកខៀវ កាញារីទ្ធ អ្នកនាំពាក្យរដ្ឋាភិបាល និងជារដ្ឋមន្ត្រីក្រសួងព័ត៌មាន បានមានប្រសាសន៍ប្រាប់ក្រុមអ្នករាយការណ៍ព័ត៌មានកាលពីរសៀលថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ថា លោកធ្វើបុណ្យកាន់បិណ្ឌនៅវត្តនគររាជបុរី នៅថ្ងៃទី៥ ខាងមុខនេះ ដោយដេកនៅទីនោះ

មួយយប់ដោយសារតែផ្លូវឆ្ងាយ ធ្វើដំណើររយៈពេល១០ម៉ោង ។

លោកខៀវ កាញារីទ្ធ បានមានប្រសាសន៍បន្តទៀតថា វត្តនគររាជបុរី នៅមានចំណាស់ជា ៦០០ឆ្នាំមកហើយ នៅខេត្តព្រះត្រពាំង ដែនដីខ្មែរកម្ពុជាក្រោម ដើម្បីជាការផ្លាស់ប្តូរការស្គាល់គ្នាទៅវិញទៅមក ។

លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍បន្តទៀតថា "ភាគច្រើនខ្មែរយើងនៅទីនេះអត់ស្គាល់កម្ពុជាក្រោមទេ អ៊ីចឹងយើងគួរតែទៅម្តង ហើយវត្ត(នគររាជបុរី) បុរាណជាងគេផង" ។ អ្នកផ្តើមទៅដាក់បិណ្ឌនៅវត្តនគររាជបុរីនោះ គឺលោក ខៀវ កាញារីទ្ធ ជាអ្នកផ្តួចផ្តើមបុណ្យ ជាមួយនឹងសម្តេចសង្ឃនៅវត្តលង្កា ។

លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍បញ្ជាក់ទៀតថា នេះគឺជាលើកទី១ហើយ ដែលលោកផ្តួចផ្តើមទៅដាក់បិណ្ឌនៅវត្តនគររាជបុរី ខេត្តព្រះត្រពាំង ឬ(ត្រាវិញ) ដែនដីកម្ពុជាក្រោម ហើយចំពោះការហែព្រះត្រៃបិដក លោករដ្ឋមន្ត្រីនឹងមានគម្រោងហែទៅប្រគេនព្រះសង្ឃគង់នៅវត្តដែនដីខ្មែរកម្ពុជាក្រោមពេលក្រោយទៀត ។

លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍បញ្ជាក់បន្តទៀតថា ការទៅកាន់បិណ្ឌនៅវត្តនគររាជបុរី គឺជាការផ្សារសាច់ផ្សារឈាមខ្មែរទាំងអស់កុំឲ្យអ្នកនេះនិយាយអីចេះ អ្នកនោះនិយាយអីចុះ ហើយអ្នកទៅជាមួយមានសេរីភាពក្នុងការនិយាយទំនាក់ទំនងជាមួយខ្មែរកម្ពុជាក្រោមនៅខេត្តព្រះត្រពាំង ។

លោក ចាច់ សេដ្ឋា អតីតព្រឹទ្ធសមាជិកនៃគណបក្ស សម រង្ស៊ី និងជាប្រធានសហគមន៍ខ្មែរ

កម្ពុជាក្រោមបានមានប្រសាសន៍ថា ការទៅដាក់បិណ្ឌនៅវត្តនគររាជបុរី ខេត្តព្រះត្រពាំង ដែនដីខ្មែរកម្ពុជាក្រោម ពីសំណាក់លោក ខៀវ កាញារីទ្ធ នោះ(៥ កញ្ញា ២០០៨) ដើម្បីឲ្យខ្មែរបានដឹងពីវប្បធម៌របស់ខ្មែរកម្ពុជាក្រោម ហើយសុំឲ្យមានដំណើរទស្សនកិច្ចរបស់មន្ត្រីរដ្ឋាភិបាលខ្មែរចុះទៅកម្ពុជាក្រោមឲ្យបានញឹកញាប់ ។

លោកថាច់ សេដ្ឋា អបអរដំណើរទៅកាន់បិណ្ឌនៅវត្តនគររាជបុរី ពីសំណាក់លោក ខៀវ កាញារីទ្ធ អ្នកនាំពាក្យរដ្ឋាភិបាល និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ។

លោកថាច់ សេដ្ឋា បានមានប្រសាសន៍បន្តថា ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមរស់នៅលើដែនដីខ្មែរកម្ពុជាក្រោម ពុំមានសេរីភាពបរិបូរណ៍ ក្នុងការគោរពប្រតិបត្តិព្រះពុទ្ធសាសនាដែលជាសាសនារបស់ជាតិឡើយ សូម្បីតែការសិក្សាអក្សរសាស្ត្រខ្មែរក៏ពុំមានផង ៕

ប្រភពព័ត៌មានៈ សារព័ត៌មានខ្មែរស្ថាបនា

២៨ សីហា ២០០៩